**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ត្រូវបានបង្កើត "**ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា**" តទៅនេះហៅថា **ធ.ស.ក.** និងសរសេរជាភាសាអង់គ្លេស Small and Medium Enterprise Bank of Cambodia ឬ SME Bank of Cambodia។

**មាត្រា២ ._**

**ធ.ស.ក.** ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋដែលមានឧបនិស្ស័យជាគ្រឹះស្ថានធនាគារ និងមានស្វ័យភាពបរិបូរណ៍ ក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។

**មាត្រា៣ ._**

**ធ.ស.ក.** មានបេសកកម្មផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៤ ._**

**ធ.ស.ក.** មានភារកិច្ច ដូចតទៅ÷

- ផ្តល់ហិរញ្ញប្បទានក្នុងលក្ខខណ្ឌអនុគ្រោះដល់សហគ្រាសធុនតូច និងមធ្យមដែលមានលក្ខណៈសមស្រប
- ទទួលប្រាក់បញ្ញើពីសាធារណជន
- ផ្តល់សេវាទូទាត់ប្រាក់
- ផ្តល់សេវាគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ជាអាទិ៍ ការកសាងសមត្ថភាព ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសក្នុងក្របខណ្ឌនៃការផ្តល់ឥណទាន
- ផ្តល់ការធានាឥណទានដល់សហគ្រាសធុនតូច និងមធ្យម
- ផ្តល់សេវាធនាគារពាណិជ្ជផ្សេងៗទៀត ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

**មាត្រា៥ ._**

**ធ.ស.ក.** ត្រូវស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ជាធរមាន។

**មាត្រា៦ ._**

**ធ.ស.ក.** មានប្រភពទុនស្របច្បាប់ ដូចខាងក្រោម÷

- ដើមទុនចុះបញ្ជីដំបូង និងដើមទុនបន្ថែមដែលផ្ដល់ដោយរដ្ឋ
- ចំណូលផ្សេងៗគ្រប់ប្រភេទដែលបានមកពីសកម្មភាពរបស់ **ធ.ស.ក.**
- ប្រាក់បញ្ញើដែលបានមកពីសាធារណជន
- ប្រាក់ដែលបានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ
- ប្រាក់ចំណូលដែលបានមកពីការលក់ ឬជួលអចលនវត្ថុ និងចលនវត្ថុរបស់ **ធ.ស.ក.** និង
- ប្រភពទុនស្របច្បាប់ផ្សេងៗ។

**មាត្រា៧ ._**

**ធ.ស.ក.** ទទួលបានបុគ្គលភាពគតិយុត្តិពេញលេញ ស្របតាមច្បាប់កំណត់ ហើយជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិទាំងឡាយ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ។

**មាត្រា៨ ._**

ទីស្នាក់ការកណ្ដាលរបស់ **ធ.ស.ក.** ស្ថិតនៅរាជធានីភ្នំពេញ និងអាចមានសាខាតាមការចាំបាច់។

## ជំពូកទី ២
## ការដឹកនាំ និងគ្រប់គ្រង

**មាត្រា៩ ._**

**ធ.ស.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន០៧រូប ដែលមានសមាសភាព ដូចតទៅ÷

| | | |
|---|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | ប្រធាន |
| - តំណាងក្រសួងពាណិជ្ជកម្ម | ០១ រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ០១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| - អគ្គនាយករបស់ **ធ.ស.ក.** | ០១ រូប | សមាជិក |
| - តំណាងបុគ្គលិករបស់ **ធ.ស.ក.** | ០១ រូប | សមាជិក |
| - តំណាងឯករាជ្យពីវិស័យឯកជន | ០១ រូប | សមាជិក |

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលដែលមានសមាសភាពពីវិស័យសាធារណៈ លើកលែងតែតំណាងបុគ្គលិក ត្រូវតែងតាំងសម្រាប់អាណត្តិ៣ឆ្នាំ ហើយអាចបន្តជាថ្មីទៀតបានដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តំណាងបុគ្គលិក ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិករបស់ **ធ.ស.ក.**។

សមាសភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់មុនអាណត្តិ តាមសំណើរបស់ក្រសួងតំណាង ក្នុងករណី សមាជិកក្រុមប្រឹក្សាភិបាល មានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួងស្ថាប័ន តំណាងបុគ្គលិក **ធ.ស.ក.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច និង/ឬត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

**មាត្រា១០ ._**

ការងារប្រចាំថ្ងៃរបស់ **ធ.ស.ក.** ត្រូវគ្រប់គ្រងដោយ **"អគ្គនាយក"** ០១ រូប ដែលត្រូវបានជ្រើសរើស ដោយឈរលើគោលការណ៍នៃការប្រកួតប្រជែង, បើកចំហ, និងតម្លាភាព ផ្អែកលើសមត្ថភាព និងបទពិសោធន៍ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ អគ្គនាយកត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១១ ._**

តួនាទីរបស់ក្រុមប្រឹក្សាភិបាល និងអគ្គនាយក **ធ.ស.ក.** ត្រូវកំណត់ដោយលក្ខន្តិកៈ។

**មាត្រា១២ ._**

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា១៣ ._**

**ធ.ស.ក.** ត្រូវមានក្របខណ្ឌអភិបាលកិច្ចសាជីវកម្មសមស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីធានាប្រសិទ្ធភាព សុខភាពហិរញ្ញវត្ថុ និងការរីកចម្រើនប្រកបដោយចីរភាព ដែលត្រូវចែងលម្អិត នៅក្នុងលក្ខន្តិកៈរបស់ **ធ.ស.ក.**។

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១៤ ._**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេល មិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារពាក់ព័ន្ធទាំងឡាយ។

**មាត្រា១៥ ._**

រៀងរាល់ឆ្នាំ មុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការ ប្រចាំឆ្នាំរបស់ **ធ.ស.ក.** តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការអនុម័តពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៦ ._**

រដ្ឋធានាចំពោះហានិភ័យណាដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៧ ._**

រយៈពេល ១៥ ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល អគ្គនាយក **ធ.ស.ក.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាលរួម ជាមួយគម្រោង ផែនការអាជីវកម្ម និង/ឬរបាយការណ៍ប្រតិបត្តិការ និង/ឬរបាយការណ៍ហិរញ្ញវត្ថុ និង/ឬឯកសារពាក់ព័ន្ធ ផ្សេងទៀតតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា១៨ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១៤ កើត ខែពិសាខ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ